ATASK គឺជាភ្នាក់ងារប្រឆាំងអំពើហិង្សាក្នុងគ្រួសារសម្រាប់ជនរងគ្រោះជាតិសាសន៍អាស៊ី និងអ្នករួចផុតពីគ្រោះថ្នាក់នៅ ញូ អ៊ីងឡែន ដោយបម្រើអតិថិជនជាភាសាអាស៊ីចំនួន 14 ភាសា។ បេសកកម្មរបស់យើងគឺដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារក្នុងចំណោមគ្រួសារ និងសហគមន៍អាស៊ី និងដើម្បីផ្តល់ក្តីសង្ឃឹមដល់អ្នករួចផុតពីគ្រោះថ្នាក់។


**បូស្តុន៖**

ប្រអប់សំបុត្រលេខ 120108

Boston, MA 02112

ទូរសព្ទ៖ (617) 338-2350

ទូរសារ៖ (617) 338-2354

**ឡូវែល៖**

ប្រអប់សំបុត្រលេខ 7259

Lowell, MA 01853

ទូរសព្ទ៖ (978) 454-3651

ទូរសារ៖ (978) 937-2355


## ខ្សែទូរសព្ទជំនួយទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ពហុភាសា 24 ម៉ោង

## (617) 338-2355

- បាំងក្លា
- វៀតណាម
- ចិនកាតាំង
- តៃវ៉ាន់
- ឥណ្ឌូណេស៊ី
- ហិណ្ឌី
- នេប៉ាល់
- អ៊ូឌូ
- ថៃ
- កាតាឡុក (ហ្វីលីពីន)
- ចិនកុកងឺ មៀន
- ខ្មែរ (កម្ពុជា)
- ជប៉ុន
- កូរ៉េ
- ម៉ានីពូរី


**គម្រោងនេះត្រូវបានគាំទ្រដោយជំនួយរដ្ឋាភិបាលលេខ 2014-WL-AX-0036 ដែលផ្តល់ដោយការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ មតិ លទ្ធផលរកឃើញ សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា ដែលបានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយ/កម្មវិធី/ពិព័រណ៍នេះគឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងយុត្តិធម៌ ការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនោះទេ។*

សំណួរសួរញឹកញាប់ ដែលសរសេរដោយកម្មវិធីតស៊ូមតិផ្នែកច្បាប់ ATASK។ កំណែចុងក្រោយ ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2016


**ASIAN TASK FORCE**
Against Domestic Violence

# ច្បាប់ស្តីពីគ្រួសារ

## សំណួរដែលសួរញឹកញាប់

## កម្មវិធីតស៊ូមតិផ្នែកច្បាប់

ខ្សែទូរសព្ទជំនួយពហុភាសា 24 ម៉ោង

**(617) 338-2355**

www.atask.org

# ត្រូវការជំនួយបន្ថែមមែនទេ?

ក្នុងករណីបន្ទាន់ សូមទូរសព្ទទៅកាន់ 911

Safelink ....................................................................1-877-785-2020

....................................................................................1-877-521-2601

Greater Boston Legal Services ................................617-371-1234

....................................................................................800-323-3205

Legal Advocacy and Resource Center, Inc...............617-603-1700

....................................................................................800-345-5297

Metro West Legal Services .......................................508-620-1830

....................................................................................800-696-1501

Northeast Legal Aid ..................................................978-458-1465

....................................................................................800-336-2262

National Lawyers Guild .............................................617-227-7008

Boston Bar Association Lawyer Referral Service ...617-742-0625

....................................................................................800-552-7046

Massachusetts Bar Association ...............................617-654-0400

....................................................................................866-627-7577

ASIAN TASK FORCE
Against Domestic Violence

# កម្មវិធីតស៊ូមតិផ្នែកច្បាប់

កម្មវិធីតស៊ូមតិផ្នែកច្បាប់របស់យើងខិតខំបំពេញចន្លោះខ្វះខាតសំខាន់ៗនៅក្នុងការផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងការប្រទូស្តកេរ្តិ៍ភេទនៃមរតកអាស៊ី ឬអាមេរិកអាស៊ី។

ចាប់តាំងពីពេលបង្កើតឡើងនៅឆ្នាំ 2009 យើងបានផ្តល់សេវាតស៊ូមតិ ភាពជាតំណាង និងការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់អតិថិជនរបស់ ATASK ដើម្បីជួយធានាសិទ្ធិស្របច្បាប់របស់ពួកគាត់ក្នុងការក្លាយជាបុគ្គលឯករាជ្យ និងមានសុវត្ថិភាព រួចផុតពីការប្រើអំណាច និងការគ្រប់គ្រងរបស់ជនបំពាន។

ប្រវត្តិសហការរបស់យើងជាមួយអង្គការតាមសហគមន៍ សាលានីតិសាស្ត្រ សេវាផ្នែកច្បាប់ និងមេធាវីជួយជនក្រីក្រ មានន័យថា យើងធ្វើការយ៉ាងហ្មត់ចត់ ដើម្បីធានាថា អ្នករួចផុតពីគ្រោះថ្នាក់មិនត្រូវបានបដិសេធក្នុងការទទួលបានភាពជាតំណាងផ្នែកច្បាប់ ជំនួយយុទ្ធសាស្ត្រ ការណែនាំ ឬការបញ្ជូនដោយជោគជ័យ។

ការបដិសេធទទួលខុសត្រូវ៖ ខ្លឹមសារក្នុងទំព័រនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាការផ្តល់ប្រឹក្សាផ្នែកច្បាប់នោះទេ។ មុននឹងអ្នកសម្រេចធ្វើសកម្មភាពណាមួយ ATASK លើកទឹកចិត្តឱ្យអ្នកស្វែងរកការប្រឹក្សាយោបល់ពីមេធាវីនៅរដ្ឋម៉ាសាឈូសេតស៍ ដើម្បីជួយអ្នកវិភាគលើស្ថានភាពពិសេស និងជាក់លាក់របស់អ្នក ដើម្បីស្វែងរកដំណោះស្រាយល្អបំផុត ដែលស្របតាមតម្រូវការរបស់អ្នក។

## តើខ្ញុំអាចលែងលះដោយរបៀបណា?

ជំហានដំបូងគឺត្រូវដាក់បណ្តឹងសុំលែងលះនៅស្រុកម៉ាសាឈូសេតស៍ ដែលអ្នកបានរស់នៅជាមួយប្តី/ប្រពន្ធរបស់អ្នក ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកនៅតែរស់នៅក្នុងស្រុកនោះដដែល។ បើមិនដូច្នោះទេ អ្នកត្រូវដាក់ពាក្យសុំលែងលះនៅស្រុកម៉ាសាឈូសេតស៍ ដែលអ្នកកំពុងរស់នៅ។

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកយល់ស្របតាមបញ្ហាទាំងអស់ ដែលទាក់ទងនឹងការលែងលះ នោះអ្នកអាចដាក់ញត្តិសុំលែងលះរួមគ្នា និងកិច្ចព្រមព្រៀងលែងលះ។

ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមិនយល់ស្របតាមការលែងលះ ឬលក្ខខណ្ឌនៃការលែងលះ អ្នកអាចដាក់បណ្តឹងសុំលែងលះតែឯង។

អ្នកត្រូវជ្រើសរើសមូលដ្ឋាន ឬ "មូលហេតុ" សម្រាប់ការលែងលះ៖

**ការលែងលះ "ដោយគ្មានកំហុស"**មានការចង់បានច្រើនសម្រាប់ការលែងលះភាគច្រើន។ អ្នកមិនចាំបាច់ប្រាប់ពីមូលហេតុសម្រាប់ការលែងលះទេ។ ជាទូទៅ វាកាត់បន្ថយពេលវេលា និងអារម្មណ៍រសាប់រសល់ និងមិនតម្រូវឱ្យផ្តល់សក្ខីកម្ម ដើម្បីបញ្ជាក់ហេតុផលនោះទេ។

**ការលែងលះ"ដោយមានកំហុស"**តម្រូវឱ្យអ្នកបញ្ជាក់ប្រាប់ទៅក្រមថា ប្តី/ប្រពន្ធរបស់អ្នកបណ្តាលឱ្យមានបញ្ហាក្នុងជីវិតអាពាហ៍ពិពាហ៍ ដោយផ្អែកលើហេតុផលមួយក្នុងចំណោមហេតុផលផ្លូវការ ឬ "មូលហេតុ" សម្រាប់ការលែងលះ។ មូលហេតុទូទៅគឺការប្រព្រឹត្តអំពើឃោរឃៅ និងបំពាន ការរត់ចោលបាត់ឈឹងរយៈពេលមួយឆ្នាំ ការផិតប្តី/ប្រពន្ធ ឬទម្លាប់ប្រមឹក និងមូលហេតុផ្សេងៗទៀត។

**បញ្ហាទូទៅទាក់ទងនឹងការលែងលះ៖**

សិទ្ធិចិញ្ចឹមកូន ផែនការថែទាំកូន (ការទៅសួរសុខទុក្ខកូន) ជំនួយហិរញ្ញវត្ថុដល់កូន និង/ឬប្តី/ប្រពន្ធ ការបែងចែកទ្រព្យសម្បត្តិ និងបំណុលក្នុងចំណងអាពាហ៍ពិពាហ៍។

**ការសុំលែងលះដោយសារការមានកំហុសអាចពន្យារពេលនៃដំណើរការលែងលះ ប៉ុន្តែវាមិនតែងតែមានផលប៉ះពាល់ជាសារវន្តមកលើលទ្ធផលនៃការលែងលះនោះទេ។**

# ប្រភព


1 អ្នកអាចរកទម្រង់បែបបទដាក់ពាក្យបណ្តឹងថ្មីៗបាននៅលើគេហទំព័រប្រព័ន្ធតុលាការរដ្ឋម៉ាសាឈូសេតស៍៖ http://www.mass.gov/courts/courtsandjudges/courts/probateandfamilycourt/forms.html#divorce.

http://www.masslegalhelp.org/children-and-families/divorce-separation-basic-info

2 http://www.masslegalhelp.org/children-and-families/child-custody-and-visitation; http://www.masslegalhelp.org/children-and-families/chapter6-custody; http://www.masslegalhelp.org/domestic-violence/wdwgfh8/can-visitation-be-safe

3 http://www.masslegalservices.org/system/files/Chapter+11+Final.pdf

4 http://www.masslegalhelp.org/children-and-families/divorce-separation-basic-info

5 http://www.masslegalhelp.org/children-and-families/chapter8-divorce; M.G.L.A. 208 § 34

## តើមានអ្វីកើតឡើងមកលើផ្ទះក្នុងចំណងអាពាហ៍ពិពាហ៍ គណនីប្រតិបត្តិការ និងទ្រព្យសម្បត្តិ និងបំណុលផ្សេងទៀត?

អ្នកនិងប្តី/ប្រពន្ធរបស់អ្នកអាចសម្រេចចិត្ត តាមរយៈកិច្ចព្រមព្រៀងអំពីរបៀបបែងចែកទ្រព្យសម្បត្តិ និងបំណុលក្នុងចំណងអាពាហ៍ពិពាហ៍ និងអ្នកដែលនឹងរស់នៅក្នុងផ្ទះគ្រួសារ។ តុលាការទំនងនឹងអនុម័តលើកិច្ចព្រមព្រៀងដែលធ្វើឡើងដោយមានការស្ម័គ្រចិត្ត និងសមហេតុផលបែបនេះ។

ទោះជាយ៉ាងណា ប្រសិនបើអ្នក និងអតីតប្តី/ប្រពន្ធរបស់អ្នកមិនអាចឈានដល់ការព្រមព្រៀងគ្នាទេ តុលាការនឹងធ្វើការសម្រេចចិត្តទាំងនេះជូនអ្នកនៅពេលជំនុំជម្រះក្តី។ ទ្រព្យសម្បត្តិទាំងអស់មិនថាជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬរួមគ្នាក្នុងអំឡុងពេលរៀបការ ត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិក្នុងជីវិតអាពាហ៍ពិពាហ៍ ដែលត្រូវធ្វើការបែងចែកប្រកបដោយសមធម៌ (ដោយយុត្តិធម៌)។ តុលាការពិចារណាលើកត្តាជាច្រើនក្នុងការធ្វើការបែងចែកប្រកបដោយសមធម៌៖ រយៈពេលនៃចំណងអាពាហ៍ពិពាហ៍ របៀបនិងពេលដែលទទួលបានទ្រព្យសម្បត្តិនោះ ការប្រព្រឹត្តរបស់ភាគីទាំងពីរក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ ចំនួននិងប្រភពចំណូល លទ្ធភាពមានការងារធ្វើ តម្រូវការរបស់ភាគី តម្រូវការរបស់កូនក្នុងបន្ទុកក្នុងចំណងអាពាហ៍ពិពាហ៍នេះ ការរួមចំណែករបស់ភាគីម្នាក់ៗក្នុងការទទួលបាន ឬរក្សាទ្រព្យសម្បត្តិ និងកត្តាផ្សេងៗទៀត។

ឋានៈអន្តោប្រវេសន៍របស់អ្នកមិនប៉ះពាល់ដល់សិទ្ធិជាម្ចាស់កម្មសិទ្ធិរបស់អ្នកលើទ្រព្យសម្បត្តិ និងទ្រព្យសកម្មក្នុងចំណងអាពាហ៍ពិពាហ៍ទេ។ 5

**សម្គាល់៖ ឯកសារនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ចូរពិគ្រោះយោបល់ជាមួយមេធាវីដែលអាចទុកចិត្តបានជានិច្ច។ គោលការណ៍ណែនាំខាងក្រោមមានលក្ខណៈទូទៅតែប៉ុណ្ណោះ ហើយអាចនឹងមិនអាចអនុវត្តបានក្នុងស្ថានភាពពិសេសរបស់អ្នក។**

## តើការលែងលះនឹងប៉ះពាល់ដល់ឋានៈអន្តោប្រវេសន៍របស់ខ្ញុំដែរឬទេ?

សម្គាល់៖ ឯកសារនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ចូរពិគ្រោះយោបល់ជាមួយមេធាវីដែលអាចទុកចិត្តបានជានិច្ច។ គោលការណ៍ណែនាំខាងក្រោមមានលក្ខណៈទូទៅតែប៉ុណ្ណោះ ហើយអាចនឹងមិនអាចអនុវត្តបានក្នុងស្ថានភាពពិសេសរបស់អ្នក។

Iប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជានិវាសនជនអចិន្ត្រៃយ៍ស្របច្បាប់ ជាទូទៅ ការលែងលះរបស់អ្នកនឹងមិនមានលទ្ធផលអវិជ្ជមានទាក់ទងនឹងអន្តោប្រវេសន៍ឡើយ។

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកសុទ្ធតែគ្មានលិខិតស្នាមទាំងពីរអ្នក អ្នកក៏អាចលែងលះដោយគ្មានលទ្ធផលអវិជ្ជមានផងដែរ។ ប្រសិនបើក្រោយមក ប្តី/ប្រពន្ធរបស់អ្នកទទួលបានឋានៈស្របច្បាប់ ឋានៈរបស់គាត់នឹងមិនប៉ះពាល់ដល់ឋានៈរបស់អ្នកទេ។

ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជានិវាសនជនអចិន្ត្រៃយ៍ ហើយអ្នកគ្មានទេ នោះការលែងលះអាចមានផលប៉ះពាល់ដល់ឋានៈអន្តោប្រវេសន៍របស់អ្នក ប្រសិនបើប្តី/ប្រពន្ធរបស់អ្នកបានដាក់ញត្តិសុំឱ្យអ្នករស់នៅសហរដ្ឋអាមេរិក។ ប

ប្រសិនបើអ្នកនៅសហរដ្ឋអាមេរិក តាមទិដ្ឋាការការងារបណ្តោះអាសន្ន សិស្សនិស្សិត ឬការស្រាវជ្រាវរបស់ប្តី/ប្រពន្ធរបស់អ្នក ការលែងលះអាចប៉ះពាល់ដល់ការស្នាក់នៅដោយស្របច្បាប់របស់អ្នកនៅសហរដ្ឋអាមេរិក។

សូមមើល *សំណួរដែលសួរញឹកញាប់អំពីអន្តោប្រវេសន៍។*

## តើមានជម្រើសផ្សេងក្រៅពីការលែងលះដែរឬទេ?

**បណ្តឹងមោឃកម្ម**ត្រូវបានប្រើ ដើម្បីលុបចោលអាពាហ៍ពិពាហ៍ ហាក់ដូច ប្តីប្រពន្ធមួយគូនេះមិនធ្លាប់រៀបអាពាហ៍ពិពាហ៍ពីមុនមកអ៊ីចឹង។ តុលាការនឹងលុបចោលអាពាហ៍ពិពាហ៍ ប្រសិនបើ 1) ប្តីប្រពន្ធជាប់ទាក់ទងនឹងគ្នាខ្លាំងពេកដោយសារជាប់សាច់ឈាមនឹងគ្នា ឬដោយសារអាពាហ៍ពិពាហ៍ ឬ 2) ប្តី ឬប្រពន្ធបានរៀបការស្របច្បាប់នៅពេលរៀបអាពាហ៍ពិពាហ៍។ តុលាការអាចលុបចោលអាពាហ៍ពិពាហ៍ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់អំពីការបោកបន្លំ ការបង្ខិតបង្ខំ ឬការខ្វះសមត្ថភាពសតិបញ្ញានៅពេលរៀបការ។

**បណ្តឹងសុំជំនួយដោយឡែក**អាចត្រូវបានប្រើប្រាស់ នៅពេលអ្នកមិនទាន់ចង់បញ្ចប់អាពាហ៍ពិពាហ៍ ប៉ុន្តែអ្នកត្រូវការជីកាជំនួយ ឬសិទ្ធិចិញ្ចឹមកូន។ អ្នកក៏មានសេរីភាពក្នុងការបែកនិងរស់នៅដោយឡែកពីប្តី/ប្រពន្ធរបស់អ្នក ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីផ្លូវការណាមួយនៅក្នុងតុលាការឡើយ។

**សន្ធានកម្ម**គឺជាជម្រើសមួយក្នុងដំណើរការលែងលះដែលមានលក្ខណៈស្លូវដេញដោល និងអាចសន្សំលុយផងដែរ។ នៅត្រង់នេះ មេធាវីមួយរូបជួយប្តីប្រពន្ធឱ្យឈានដល់ការព្រមព្រៀងគ្នាលើបញ្ហាទាំងអស់ រួចធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងលែងលះ ដែលទទួលយកទាំងសងខាង ប៉ុន្តែមិនតំណាងឱ្យភាគីណាមួយឡើយ។ ជម្រើសនេះស័ក្តិសមសម្រាប់តែប្តីប្រពន្ធដែលមានអំណាយស្មើគ្នានៅក្នុងជីវិតអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។

## តើខ្ញុំនឹងបាត់បង់កូនរបស់ខ្ញុំនៅក្នុងការលែងលះដែរឬទេ?

ជាញឹកញាប់ អ្នកបំពាននឹងគំរាមកំហែងជនរងគ្រោះរបស់ខ្លួន ដោយនិយាយថា ជនរងគ្រោះនឹងបាត់បង់កូន និងមិនជួបពួកគេម្តងទៀតឡើយ។ ទោះជាយ៉ាងណា ការពិតគឺថា ឪពុកម្តាយភាគច្រើនមិន "បាត់បង់" កូនរបស់ពួកគាត់នោះទេ។ ផ្ទុយទៅវិញ ជាញឹកញាប់ តុលាការនៅម៉ាសាឈូសេតស៍ប្រើប្រាស់ "រយៈពេលថែទាំកូន" ដើម្បីរៀបរាប់អំពីការផ្លាស់ប្តូរសិទ្ធិចិញ្ចឹមកូនជារូបវន្ត។

នៅម៉ាសាឈូសេតស៍ មានសិទ្ធិចិញ្ចឹមកូនចំនួនពីរប្រភេទ៖

**សិទ្ធិចិញ្ចឹមកូនជារូបវន្ត**គឺជាសិទ្ធិក្នុងការទទួលបានកូនរបស់អ្នកឱ្យរស់នៅជាមួយអ្នកជាចម្បង។ ជាញឹកញាប់ ពាក្យ "រយៈពេលថែទាំកូន" ត្រូវបានប្រើប្រាស់ជំនួសឱ្យ "សិទ្ធិចិញ្ចឹមកូនជារូបវន្ត" ហើយនិងរៀបរាប់អំពីកាលវិភាគប្រចាំសប្តាហ៍ ដែលឪពុកម្តាយម្នាក់ៗមានជាមួយកូន។

**សិទ្ធិចិញ្ចឹមកូនស្របច្បាប់**គឺជាសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ ដែលប៉ះពាល់ដល់សុខុមាលភាពផ្នែកសាសនា ស្មារតី ការអប់រំ ឬសុខភាពរបស់កូន។

ប្រសិនបើអ្នក និងប្តី/ប្រពន្ធរបស់អ្នកមិនឯកភាពចំពោះសិទ្ធិចិញ្ចឹមកូនទេ ចៅក្រមនឹងធ្វើសេចក្តីសម្រេច ដោយផ្អែកលើ "ឧត្តមប្រយោជន៍" របស់កូន។ ចៅក្រមនឹងថ្លឹងថ្លែងកត្តាជាច្រើនដូចជា សុខភាពបច្ចុប្បន្ន និងស្ថិរភាពរបស់មាតា ឬបិតា និងកូន អត្ថិភាពនៃការបំពានលើរាងកាយ ឬការសេពគ្រឿងស្រវឹង ឬការធ្វេសប្រហែស និងថាតើមាតា ឬមាតាគឺជាអ្នកថែទាំកូនតែឯង ឬចម្បង។ នៅក្នុងករណីភាគច្រើន មាតាបិតាទាំងពីរ រួមទាំងដៃគូបំពានដែរ នឹងមានរយៈពេលថែទាំកូនខ្លះៗជាមួយកូន ទោះបីជាករណីនេះមានការឃ្លាំមើល ដើម្បីសុវត្ថិភាពរបស់ក្មេង។

**ប្រសិនបើ**អ្នករៀបការ ហើយមិនមានដីកាបញ្ជាក់ពីសិទ្ធិចិញ្ចឹមកូនជាក់លាក់ទេ នោះមាតាបិតាទាំងពីរមានសិទ្ធិចិញ្ចឹមកូនជារូបវន្ត និងស្របច្បាប់រួមគ្នា។

**ប្រសិនបើ**អ្នកមិន*រៀបការទេ ហើ*យមិនមានដីកាបញ្ជាក់ពីសិទ្ធិចិញ្ចឹមកូនជាក់លាក់ទេ នោះម្តាយមានសិទ្ធិចិញ្ចឹមកូនជារូបវន្ត និងស្របច្បាប់ទាំងស្រុង។

ក្នុងករណីមានការបង្ហាញថា មានគ្រោះថ្នាក់ខ្លាំង ឬមានបទល្មើសបំពានដោយឪពុកឬម្តាយ តុលាការអាចផ្អាករយៈពេលថែទាំកូនជាបណ្តោះអាសន្ន ឬដកសិទ្ធិថែទាំកូនរបស់ឪពុកឬម្តាយដែលបង្កគ្រោះថ្នាក់ជារៀងរហូត។

ប្រសិនបើអ្នកខ្លាចថា ប្តី/ប្រពន្ធរបស់អ្នករត់គេចជាមួយកូនរបស់អ្នកទៅរដ្ឋផ្សេង ឬប្រទេសផ្សេង អ្នកអាចស្នើឱ្យតុលាការដោះស្រាយបញ្ហានេះ និងអនុវត្តការប្រុងប្រយ័ត្នជាមុនដូចជា ការរក្សាទុកលិខិតឆ្លងដែនរបស់កូន ឬការសួរសុខទុក្ខកូនដោយមានការឃ្លាំមើល។

## តើខ្ញុំអាចទុកកូនឱ្យនៅជាមួយខ្ញុំបានដែរឬទេ ប្រសិនបើខ្ញុំមិនមែនជានិវាសនជនអចិន្ត្រៃយ៍ ឬគ្មានសញ្ជាតិអាមេរិក?

ទោះបីជាអ្នកមិនមានឋានៈអន្តោប្រវេសន៍ តាមបច្ចេកទេស អ្នកនៅតែមានសិទ្ធិចិញ្ចឹមកូនដូចពលរដ្ឋអាមេរិកដែរ។ ស្តង់ដារ "ឧត្តមប្រយោជន៍" របស់កូន និងច្បាប់ផ្សេងទៀត ដែលគ្របដណ្តប់សិទ្ធិចិញ្ចឹមកូន និងថែទាំកូន ត្រូវបានអនុវត្តដូចគ្នា ទោះបីជាអ្នកគ្មានលិខិតស្នាម ឬគ្មានសញ្ជាតិអាមេរិកក៏ដោយ។ ចៅក្រមនឹងធ្វើសេចក្តីសម្រេចចិត្ត ផ្អែកលើឧត្តមប្រយោជន៍របស់កូន ដោយមិនគិតពីឋានៈអន្តោប្រវេសន៍របស់មាតាបិតាឡើយ។ទោះជាយ៉ាងណា ប្រសិនបើអ្នកគ្មានលិខិតស្នាម ប្តី/ប្រពន្ធរបស់អ្នកអាចបង្ហាញក្តីបារម្ភអំពីការចាប់ជំរិត ការបញ្ជូនចេញពីប្រទេស និងការត្រឡប់ទៅប្រទេសកំណើតរបស់អ្នកវិញជាមួយកូនរបស់អ្នក ដែលចៅក្រមអាចនឹងដោះស្រាយ។

## តើខ្ញុំនឹងទទួលបានជំនួយហិរញ្ញវត្ថុពីប្តី/ប្រពន្ធរបស់ខ្ញុំទេ?

ការជួយចិញ្ចឹមកូន៖ ប្រសិនបើអ្នកមានសិទ្ធិចិញ្ចឹមកូនជារូបវន្ត ឬមានរយៈពេលថែទាំកូនច្រើនជាង នោះប្តី/ប្រពន្ធរបស់អ្នកមានកាតព្វកិច្ចតាមច្បាប់ ក្នុងការបង់ថ្លៃចិញ្ចឹមកូនរបស់អ្នក ទោះបីជាគាត់មិនធ្វើការ ឬជួបកូន*ក៏ដោយ។ ចំនួនទឹកប្រាក់ជួយចិញ្ចឹមកូននេះត្រូវបានគណនា*ដោយផ្អែកលើរូបមន្តដែលបានកំណត់មួយ ដែលតម្រូវដោយរដ្ឋ ទោះបីតុលាការមានឆន្ទានុសិទ្ធិក្នុងការកែសម្រួលចំនួននេះ។

ប្រសិនបើអ្នកមានសិទ្ធិចិញ្ចឹមកូនជារូបវន្តរួមគ្នា ឬរយៈពេលថែទាំកូនរបស់អ្នកស្មើគ្នា នោះឪពុកឬម្តាយដែលមានប្រាក់ចំណូលខ្ពស់ជាងអាចត្រូវបានតម្រូវឱ្យបង់ប្រាក់ជួយចិញ្ចឹមកូនដែលបានកែសម្រួលទៅឱ្យឪពុក/ម្តាយដែលមានប្រាក់ចំណូលទាបជាង។

ការជួយដល់ប្តី/ប្រពន្ធ៖ ការទទួលបានប្រាក់ឧបត្ថម្ភ ឬប្រាក់ជួយប្តី/ប្រពន្ធរបស់អ្នកអាស្រ័យលើកត្តាជាច្រើនដូចជាអាយុ ការអប់រំ ចំណូល និងលទ្ធភាពរកចំណូលរបស់ភាគី និងប្រវត្តិការងារនៅក្នុង/នៅក្រៅផ្ទះរបស់ប្តី/ប្រពន្ធម្នាក់ៗជាដើម។

ចំនួន និងរយៈពេលនៃការជួយប្តី/ប្រពន្ធទាំងឡាយ ដែលបានធ្វើតាមដីកាអាស្រ័យលើរយៈពេលនៃអាពាហ៍ពិពាហ៍ និងភាពជាដៃគូ តម្រូវការរបស់ប្តី/ប្រពន្ធដែលទទួលប្រាក់ និងសមត្ថភាពក្នុងការផ្តល់ប្រាក់របស់ប្តី/ប្រពន្ធដែលផ្តល់ប្រាក់។